**សលាកប័ត្រព័ត៌មាន ៖** កម្រងឯកសារស្តីពីករណីសិក្សា ៖ ការប្រើប្រាស់កម្លាំងពលកម្មទណ្ឌិតក្នុងការបណ្តេញចេញដោយបង្ខំ
**កាលបរិច្ឆេទ ៖** ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២
**រូបភាពរួម ៖** ការប្រើប្រាស់ទណ្ឌិតដើម្បីអនុវត្តការបណ្តេញចេញដោយបង្ខំ ក្នុងខេត្តព្រះសីហនុ បង្ហាញឲ្យឃើញអំពីអាកប្បកិរិយាដោយបំពាន និងកង្វះភាពទទួលខុសត្រូវ របស់រដ្ឋក្នុងការគ្រប់គ្រងពលកម្មទណ្ឌិត និងអនុវត្តការបណ្តេញចេញដោយបង្ខំ ដែលនេះជាការរំលោភបំពានសិទ្ធិស្របច្បាប់ និងសិទ្ធិមនុស្សរបស់ទណ្ឌិត និងប្រជាពលរដ្ឋដែលរស់នៅលើដីនោះ ។

## សេចក្តីផ្តើម

កាលពីខែឧសភា ប្រជាពលរដ្ឋដែលរស់នៅលើដីក្នុងខេត្តសីហនុ បានរងគ្រោះដោយការរុះរើលំនៅដ្ឋានរបស់ពួកគេ ដែលនេះជាឧទាហរណ៍មួយផ្សេងទៀត ក្នុងចំណោមការបណ្តេញចេញដោយហិង្សាជាច្រើនករណី ដែលបានកើតឡើងក្នុងពេលថ្មីៗនេះ នៅព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") ។ ការបណ្តេញចេញនេះ មានលក្ខណៈខុសប្លែក ដោយមានការប្រើប្រាស់ទណ្ឌិតដើម្បីអនុវត្តការបណ្តេញចេញ ដែលនេះជាការរំលោភបំពានច្បាប់ និងអនុសញ្ញាស្តីពីសិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធ ។ ខណៈពេលដែលការប្រើប្រាស់ពលកម្មទណ្ឌិតត្រូវបានរិះគន់ថាជាអំពើកេងប្រវ័ញ្ចលើកម្លាំងពលកម្មទណ្ឌិត ការប្រើប្រាស់ទណ្ឌិតក្នុងការបណ្តេញចេញដោយបង្ខំ បង្កឲ្យមានជនរងគ្រោះពីរប្រភេទ ៖ គឺទណ្ឌិតផ្ទាល់ ដែលត្រូវបានស្នើ ឬបញ្ជាឲ្យប្រព្រឹត្តអំពើហិង្សា ព្រមទាំងការរំលោភបំពានសទ្ធិមនុស្ស និងអ្នកដែលត្រូវគេបណ្តេញចេញដែលជាមុខសញ្ញានៃអំពើហិង្សា ។ សលាកប័ត្រនេះត្រូវបានតាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅប្រទេសកម្ពុជា ។

## ហេតុការណ៍

នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២ កងកម្លាំងយោធាប្រដាប់ដោយអាវុធប្រមាណ៧០នាក់ និងទណ្ឌិត២០នាក់ បានបណ្តេញប្រជាពលរដ្ឋចេញពីភូមិ១៦ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ (ដែលបានរាយការណ៍លើវែបសាយត៍ព័ត៌មានខេមរ៉ូចេញថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២) ។ ទណ្ឌិតត្រូវបានបញ្ជាឲ្យរុះរើលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ និងដំណាំនៅលើដី ដែលត្រូវបានរក្សាទុកសម្រាប់សាងសង់ពន្ធនាគារ ។ យ៉ាងហោចណាស់ប្រជាពលរដ្ឋម្នាក់ដែលរស់នៅលើដីនោះ ឈ្មោះ ម៉ម វណ្ណា អាយុ៥២ឆ្នាំ រងរបួសត្រង់ក្បាល និងសន្លប់បាត់បង់ស្មារតី បន្ទាប់ពីគាត់ព្យាយាមរារាំងមិនឲ្យទណ្ឌិតរុះរើលំនៅដ្ឋាន និងដំណាំរបស់គាត់ ។ ប្រជាពលរដ្ឋដែលរស់នៅលើដីនោះបានឲ្យដឹងថា ពួកគេមិនបានទទួលសំណង ឬយន្តការដោះស្រាយណាមួយឡើយ ហើយមិនមានព័ត៌មានជាក់លាក់បង្ហាញថាតើមានការពិភាក្សាជាមុនជាមួយប្រជាពលរដ្ឋដែលរស់នៅលើដីឬយ៉ាងណាទេ ។

## ពលកម្មទណ្ឌិត

ការងារសម្រាប់ទណ្ឌិត ជាទូទៅត្រូវបានចាត់ទុកថាជាផ្នែកដ៏សំខាន់មួយនៃរបរពន្ធនាគារ ។ ខណៈពេលការងារនេះផ្តល់អត្ថប្រយោជន៍ដល់ទណ្ឌិត ជាជាងការដាក់ទណ្ឌកម្ម ការងារនេះចៀសវាងភាពខ្ជិលច្រអូស និងផ្តល់ជំនាញដល់ទណ្ឌិត ព្រមទាំងអាចសម្របសម្រួលឲ្យពួកគេវិលត្រឡប់មករស់នៅក្នុងសង្គមវិញដោយជោគជ័យ ដែលនេះអាចប្រតិបត្តិដើម្បីចៀសវាងមិនឲ្យពួកគេប្រព្រឹត្តបទឧក្រិដ្ឋជាថ្មីម្តងទៀត (ការប្រព្រឹត្តបទល្មើសដដែលៗ) ។ នៅប្រទេសកម្ពុជា ការប្រើប្រាស់ពលកម្មទណ្ឌិតសម្រាប់ប្រយោជន៍ពាណិជ្ជកម្មឯកជន ត្រូវបានរិះគន់យ៉ាងធ្ងន់ធ្ងរ ប៉ុន្តែការប្រើប្រាស់កម្លាំងពលកម្មទណ្ឌិតក្នុងករណីនេះត្រូវបានយកមកជជែកវែកញែកថាមានលក្ខណៈកេងប្រវ័ញ្ច និងរំលោភបំពានកាន់តែខ្លាំង ។

វគ្គបំណងពីរនៃច្បាប់ស្តីពីពន្ធនាគារឆ្នាំ២០១១ ("ច្បាប់ពន្ធនាគារ") គឺការផ្តល់ *"ការអប់រំ កែប្រែ ស្តារនីតិសម្បទា ដើម្បីធ្វើសមាហរណកម្មជនជាប់ឃុំទៅក្នុងសង្គមវិញ និងទប់ស្កាត់ការប្រព្រឹត្តបទល្មើសសាជាថ្មី"* និង *"គ្រប់គ្រងជនជាប់ឃុំឲ្យធានាបានសន្តិសុខ សុវត្ថិភាព សុខភាព និងមនុស្សធម៌ស្របតាមគោលការណ៍អន្តរជាតិ ..."* ។ ពលកម្មទណ្ឌិតត្រូវបានគ្រប់គ្រងតាមមាត្រា៦៨ ដែលបានចែងថា *"ទណ្ឌិតដែលមានកម្រិតសន្តិសុខទាប ហើយត្រូវបានវាយតម្លៃថាមានសមត្ថភាពកាយសម្បទា ត្រូវបានចាត់តាំងឲ្យធ្វើការងារពលកម្មប្រចាំថ្ងៃនៅក្នុងពន្ធនាគារ ឬការងារជាអត្ថប្រយោជន៍សម្រាប់សហគមន៍ និងផលប្រយោជន៍សាធារណៈ ឬចាត់តាំងឲ្យចូលរួមក្នុងកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ"* ។ ក្នុងចំណោមប្រភេទការងារទាំងនោះ ការចូលរួមរបស់ទណ្ឌិតក្នុងការបណ្តេញចេញ អាចចាត់ទុកថាស្ថិតនៅក្នុងប្រភេទការងារដែលផ្តល់ "អត្ថប្រយោជន៍សាធារណៈ" ដោយមូលហេតុថាជាការងារសាធារណៈ (ពន្ធនាគារ) ដែលស្នើទាមទារដី ប៉ុន្តែការវិភាគនោះមិនមានភាពជាក់លាក់ និងអាស្រ័យលើការបកស្រាយដែលមិនប្រាកដប្រជាអំពីវាក្យស័ព្ទមិនជាក់លាក់ដែលមានតាំងពីដើមមក ។ ពាក្យថា "ប្រយោជន៍សាធារណៈ" គួរតែត្រូវបានបកស្រាយ ដើម្បីឲ្យពាក្យនេះរួមបញ្ចូលតែការងារដែលផ្តល់ប្រយោជន៍សាធារណៈដោយផ្ទាល់ ដូចជាការថែរក្សាទ្រព្យសម្បត្តិសាធារណៈ ឬការស្ថាបនាសម្ភារៈក្នុងថ្នាក់រៀន ។

ច្បាប់អន្តរជាតិមានលក្ខណៈជាក់លាក់ជាងនេះ ទាក់ទងនឹងស្ថានភាព និងប្រភេទនៃការងារដែលទណ្ឌិតអាចធ្វើបាន ។ បទបញ្ជាកម្រិតអប្បបរិមាដែលត្រឹមត្រូវតាមមាត្រដ្ឋាន សម្រាប់ការប្រណិបត្តិអ្នកទោស (អនុម័តដោយសមាជអង្គការសហប្រជាជាតិដំបូងស្តីពីការចៀសវាងបទឧក្រិដ្ឋ និងការចាត់ទុកឧក្រិដ្ឋជន ដែលមានការឯកភាពពីក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម ដោយសេចក្តីសម្រេចលេខ ៦៦៣ សេ (២៤) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៥៧ និងសេចក្តីសម្រេចលេខ២០៧៦ (៦២) ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧៧) បានចែងថា ទណ្ឌិតមិនត្រូវ *"ស្ថិតនៅក្រោមការរងគ្រោះ"* ហើយការងារគួរ *"រក្សា ឬបង្កើនសមត្ថភាពរបស់ទណ្ឌិតក្នុងការស្វែងរកជីវិភាពដ៏ត្រឹមត្រូវមួយបន្ទាប់ពីទណ្ឌិតត្រូវបានដោះលែង"* តាមដែលអាចធ្វើទៅបាន ដែលស្របទៅនឹងវត្ថុបំណងទាំងពីរនៃច្បាប់ស្តីពីពន្ធនាគារ ដូចបានបញ្ជាក់ខាងលើ ។ ការតម្រូវឲ្យទណ្ឌិតចូលរួមក្នុងការបណ្តេញចេញ ដែលជាព្រឹត្តិការណ៍ដែលគួរឲ្យបារម្ភ និងការដើរតួនាទីជាភ្នាក់ងាររដ្ឋក្នុងការបន្តការរំលោភបំពានសិទ្ធិមនុស្ស ប្រឆាំងនឹងប្រជាពលរដ្ឋដទៃទៀត នឹងបង្កឲ្យមាន "ការរងគ្រោះ" យ៉ាងពិតប្រាកដ ។ ការងារបែបនេះក៏មិនអាចឲ្យទណ្ឌិតចាប់យកជំនាញ ដែលអាចជួយពួកគេឲ្យកសាងជីវភាពបានឡើយ ។ ផ្ទុយទៅវិញ ការចូលរួមក្នុងអំពើហិង្សាដែលរដ្ឋអនុញ្ញាត ដើម្បីទទួលបានផលប្រយោជន៍ ទំនងជានឹងបណ្តុះឲ្យមានការមិនគោរពអ្នកដទៃ និងជំរុញឲ្យមានការប្រព្រឹត្តបទល្មើសសាជាថ្មី ។

## ការបណ្តេញចេញ

ដោយមិនគិតពីសិទ្ធិទទួលបានទ្រព្យសម្បត្តិស្របច្បាប់របស់ប្រជាពលរដ្ឋដែលរស់នៅលើដី ច្បាប់ និងអនុសញ្ញាអន្តរជាតិស្តីពីការបណ្តេញចេញទាមទារថា ការប្រើប្រាស់អំពើហិង្សាអាចត្រូវបានធ្វើឡើងតែក្នុងដំណាក់កាលចុងក្រោយប៉ុណ្ណោះ ហើយអំពើហិង្សានោះត្រូវតែសមហេតុផល និងមានលក្ខណៈសមាមាត្រ ។ ទោះបីជាកម្ពុជាមិនទាន់មានបទបញ្ជា និងច្បាប់ដែលមានលក្ខណៈទូលំទូលាយសម្រាប់គ្រប់គ្រងការបណ្តេញចេញដោយបង្ខំក៏ដោយ មាត្រា២៥៣នៃច្បាប់ភូមិបាលឆ្នាំ២០០១ចែងថា ការប្រើអំពើហិង្សាលើ *"ម្ចាស់ពិតប្រាកដនៃអចលនទ្រព្យ មិនថាសិទ្ធិកាន់កាប់ដីរបស់អចលនទ្រព្យត្រូវបានផ្តល់ជូន ឬកំពុងស្ថិតនៅក្នុងជម្លោះនោះទេ"* គឺជាបទល្មើស ។ បន្ថែមលើនេះទៀត ទាំងច្បាប់ភូមិបាលឆ្នាំ២០០១ និងច្បាប់ស្តីពីអស្សាមិករណ៍ឆ្នាំ២០១០ចែងថា មានតែ "អាជ្ញាធរមានសមត្ថកិច្ច" ដែលដើរតួនាទីជំនួសរដ្ឋ និងនីតិបុគ្គលសាធារណៈទេ ដែលអាចអនុវត្តការបណ្តេញចេញបាន ។ សូម្បីតែក្នុងកាលៈទេសៈដែលមានការគ្រប់គ្រង ឬអមដោយមន្ត្រីក៏ដោយ ក៏ទណ្ឌិតមិនអាចត្រូវបានចាត់ទុកថាជា "អាជ្ញាធរមានសមត្ថកិច្ច" និងអាចដើរតួនាទីជំនួសរដ្ឋបានឡើយ ។ ករណីនេះមិនសមស្របទាល់តែសោះ ដែលអ្នកដែលត្រូវបានគេផ្តន្ទាទោសពីបទឧក្រិដ្ឋល្មើសនឹងច្បាប់ និងបទបញ្ជា ត្រូវបានអនុញ្ញាតឲ្យអនុវត្តប្រតិបត្តិការរបស់រដ្ឋក្នុងការបង្កឲ្យមានភាពអយុត្តិធម៌ និងភាពគ្មានសណ្តាប់ធ្នាប់ និងអាចចាត់ទុកជាការរំលោភបំពានសិទ្ធិមនុស្ស ។ មិនមានគេដឹងច្បាស់អំពីអត្តចរិតរបស់ទណ្ឌិតឡើយ ប៉ុន្តែក៏មិនមានការបដិសេធថា ក្រុមទណ្ឌិតមួយចំនួនត្រូវបានផ្តន្ទាទោសពីបទល្មើសដោយហិង្សាឡើយ ។ ការរួមបញ្ចូលក្រុមទណ្ឌិតបែបនេះក្នុងស្ថានភាពអំពើហិង្សា គឺមានតែបង្កើនហានិភ័យក្នុងការអនុវត្តន៍ការបណ្តេញចេញដោយហិង្សា ហើយបង្កឲ្យមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋដែលកាន់កាប់ដីនោះ ។

## សេចក្តីសន្និដ្ឋាន

ការចូលរួមរបស់ទណ្ឌិតក្នុងការបណ្តេញចេញគឺជាការរំលោភបំពានច្បាប់ភូមិបាល ច្បាប់អន្តរជាតិស្តីពីស្ថានភាពការងាររបស់ទណ្ឌិត និងបទប្បញ្ញត្តិនៃច្បាប់ភូមិបាលឆ្នាំ២០០១ និងច្បាប់ស្តីពីអស្សាមិករណ៍ ពាក់ព័ន្ធនឹងបញ្ហាដែលថា បុគ្គលណាអាចអនុវត្តន៍ការបណ្តេញចេញ និងការប្រើប្រាស់ហិង្សាបាន ។ ដោយមិនគិតពីភាពស្របច្បាប់នៃទិដ្ឋភាពផ្សេងៗនៃការបណ្តេញចេញ ការប្រើទណ្ឌិតឲ្យអនុវត្តការបណ្តេញចេញ គឺមិនសមស្របទាល់តែសោះ និងជាការរំលោភបំពានអំណាចបង្ខំរបស់រដ្ឋចំពោះទណ្ឌិត ដែលត្រូវបានគេរិះគន់យ៉ាងធ្ងន់ធ្ងរ ហើយថែមទាំងបំពានលើលិខិត និងស្មារតីនៃច្បាប់ពាក់ព័ន្ធនឹងការបណ្តេញចេញ និងពលកម្មពន្ធនាគារ ។ ការធ្វើបែបនេះបង្ហាញឲ្យឃើញពីការមិនយកចិត្តទុកដាក់ទាំងស្រុងចំពោះជនរងគ្រោះទាំងពីរក្រុមនេះ ដែលជាទណ្ឌិត និងប្រជាពលរដ្ឋដែលកាន់កាប់ដីនោះ ព្រមទាំងសេចក្តីថ្លៃថ្នូរពីកំណើតរបស់ពួកគេ ដែលបានកើតជាមនុស្ស ។ ម.ស.ម.ក អំពាវនាវឲ្យមានការបញ្ឈប់ការអនុវត្តន៍បែបនេះជាបន្ទាន់ ព្រមទាំងការស៊ើបអង្កេតការបណ្តេញចេញបែបនេះ និងការបណ្តេញចេញដែលមានលក្ខណៈស្រដៀងគ្នាដទៃទៀត ។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង លោក អ៊ូ វីរៈ តាមរយៈទូរស័ព្ទ (+៨៥៥ (0) ១២ ៤០ ៤០ ៥១) ឬអ៊ីម៉ែល ouvirak@cchrcambodia.org ឬ លោក ចន ខហ្វឡែន (+៨៥៥ (0) ៨៩ ៥៨ ៣៥ ៩0) ឬអ៊ីម៉ែល johncoughlan@cchrcambodia.org ។**